## វេទិការសាធារណៈ ជួបសំណេះសំណាលនិងស្វែងយល់ពីតម្រូវការ និងសំណូមពរ ក្នុងមូលដ្ឋាន ឃុំ សង្កាត់ ស្រុក ក្រុង ខេត្តកំពត






ក្នុងទីធ្លាវត្តចក្រីទីង ស្ថិតក្នុងស្រុកទឹកឈូ ខេត្តកំពត នៅរសៀលថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៤ មានរៀបចំវេទិការសាធារណៈជួបសំណេះសំណាល និងស្វែងយល់ពីតម្រូវការ និងសំណូមពររបស់ប្រជាពលរដ្ឋ ក្នុងមូលដ្ឋាន ឃុំ សង្កាត់ ស្រុក ក្រុង នៃខេត្តកំពត ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ

ចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា ខេត្តកំពត ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ ជាសមាជិកក្រុមការងារ តំណាងអជ្ញាធរដែនដី ព្រមទាំងប្រជាពលរដ្ឋមូលដ្ឋានយ៉ាងច្រើនកុះករ ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរខេត្តកំពត ក្នុងការអភិវឌ្ឍន៍ខេត្តទទួលបាននូវភាពរីកចម្រើនគួរឱ្យកត់សំគាល់ ដោយទទួលបានការចាប់អារម្មណ៍មកទស្សនាទាំងភ្ញៀវជាតិ និងអន្តរជាតិ ក្នុងខេត្តទេសចរណ៍នេះ យ៉ាងច្រើនពីមួយឆ្នាំទៅមួយឆ្នាំ ។ ជាមួយគ្នានេះ ឯកឧត្តម ប្រធានក្រុមការងារថ្នាក់ជាតិ ក៏បានកោតសរសើរចំពោះប្រជាពលរដ្ឋខេត្តកំពតទាំងមូល ដែលបានអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការចូលរួមការបោះឆ្នោត និងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ។ ទន្ទឹមនិងនេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានលើកឡើងពីកិច្ចខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយភាពវាងវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការអភិវឌ្ឍន៍ប្រទេស និងកសាងខឿនសេដ្ឋកិច្ចជាតិ ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ ឯកឧត្តម បានបញ្ជាក់បន្ថែមថាៈការអភិវឌ្ឍន៍ប្រទេសជាតិ មិនអាចកាត់ផ្តាច់ពីការចូលរួមរបស់ប្រជាពលរដ្ឋបានឡើយ ក្នុងសង្គមប្រជាធិបតេយ្យ ។ ក្នុងនោះការអនុវត្តកិច្ចការទាំងឡាយរបស់រដ្ឋ ពិតជាមានកង្វះខាត និងភាពចន្លោះប្រហោងណាមួយជៀសមិនរួច ។ ដូច្នេះ ក្នុងវេទិការសាធារណៈនេះ ឯកឧត្តម បានស្នើឱ្យប្រជាពលរដ្ឋលើកឡើងនូវកង្វល់នានាជាក់ស្តែងដែលកើតមានឡើងក្នុងមូលដ្ឋានរបស់ខ្លួន ដោយបញ្ចេញមតិត្រង់ទៅត្រង់មក ក្នុងន័យស្ថាបនា ពីព្រោះនេះជាការចូលរួមអនុវត្តនូវសិទ្ធិបញ្ចេញមតិ និងជាការចូលរួមអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផងដែរ ។









តាមរយៈការបើកឱកាសឱ្យប្រជាពលរដ្ឋឡើងថ្លែងពីកង្វល់នានារបស់ពួកគាត់ អង្គវេទិកាបានទទួលនូវសំណួរ និងបញ្ហាមួយចំនួន រួមមានៈបញ្ហាការពន្លឿនគម្រោងកសាងផ្លូវក្នុងមូលដ្ឋាន-ការជួយជួសជុលផ្លូវចូលទៅកាន់វត្តចក្រីទីង-បញ្ហាការយកថវិកាក្នុងការអនុវត្តគម្រោងសង់បង្គន់អនាម័យជនបទ និងគោលនយោបាយជួយជនពិការរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ទាក់ទងនិងសំណួរ និងបញ្ហាខាងលើ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបញ្ជាក់ថាៈជាបញ្ហាដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់បំផុត លើការកសាងហេដ្ឋារចនាសម្ព័ន្ធ និងអនាម័យជនបទ ហើយបញ្ហាខាងលើនេះ ជាបញ្ហាដែលយើងអាចដោះស្រាយបាន ។ ឯកឧត្តម បានស្នើឱ្យអាជ្ញាធរមូលដ្ឋានចុះពិនិត្យស្រាវជ្រាវនិងពិនិត្យលទ្ធភាពដោះស្រាយតាមការជាក់ស្តែង ។ ដោយឡែកទាក់ទងនិងគោលនយោបាយជួយជនពិការរបស់រាជរដ្ឋាភិបាល ឯកឧត្តម បានបញ្ជាក់ថាៈ រាជរដ្ឋាភិបាលកម្ពុជា មានគោលនយោបាយច្បាស់លាស់ ដូចជាៈការបែងចែកដីលំនៅដ្ឋាន និងដីបង្កបង្កើនផល-

បង្កើតមជ្ឈមណ្ឌលស្តារនីតិសម្បទានិងគោលនយោបាយកំណត់ភាគរយក្នុងការជ្រើសរើសប្រភេទជនពិការឱ្យបម្រើក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលជាដើម ។



គួរបញ្ជាក់ថាៈបញ្ហាទាំងអស់ខាងលើនេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានតម្រូវឱ្យអជ្ញាធរមូលដ្ឋាន ឃុំ សង្កាត់ ស្រុក ចូលរួមបកស្រាយជូនប្រជាពលរដ្ឋ ។ ដោយឡែក ឯកឧត្តម **ខូយ ឃុនហ៊ួ** អភិបាល នៃគណៈអភិបាលខេត្តកំពត ក៏បានឡើងបញ្ជាក់មុខប្រជាពលរដ្ឋ ដោយចាត់តាំងឱ្យនាយករដ្ឋបាលសាលាខេត្ត ដឹកនាំក្រុមការងារចុះស្រាវជ្រាវ និងពិនិត្យលទ្ធភាពដោះស្រាយបញ្ហានេះជាបន្ទាន់ ។